គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 / 12 942 019, Fax: (855) 23 883 750
E-mail: comfrel@online.com.kh or comfrel@forum.org.kh Site: http://www.comfrel.org

ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក ធុន សារាយ
Mr. THUN SARAY
ជាតំណាងទី១ និង
ប្រធាន ADHOC

លោកស្រី អ៊ុង ចាន់ថុល
Ms. OUNG Chanthol
ជាតំណាងទី២ និង
នាយិកា CWCC

លោក យឹម ប៉ូ
Mr. YIM Po អគ្គហិរញ្ញិក
និងនាយក CCPCR

លោក សុក សំអឿន
Mr. SOK Sam Oeun
នាយក CDP

លោកស្រី ទីវ សារ៉ាយ៉េត
Ms. TIV Sarayet
សហនាយិកា WMC

លោក យង់ គិមអេង
Mr. YONG Kim Eng
ប្រធាន KYA

លោក អ៊ុក វណ្ណដេត
Mr. OUK Vandeth
នាយក LAC

លោក ស៊ីល វិនេត្រ
Mr. SIL Vinet នាយក SEDOC

លោក ភួង សិទ្ធិ
Mr. PHUONG Sith

លោក សេន សែត
Mr. SEN Set

លោក មុំ សារិន
Mr. MOM Sarin
នាយក KKKHRA

លោក ទូច ទុម
Mr. Touch Tum
នាយក VIGILANCE

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលសង្កេតលើបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៦

*ភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦*

ក្នុងកំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ ២០០៦ និងការបិទផ្សាយបញ្ជីដំបូង ចាប់ពីថ្ងៃទី ១ តុលា ដល់ថ្ងៃទី ១៥ វិច្ឆិកា ២០០៦ គណៈកម្មាធិការ **ខុមហ្វ្រែល** បានពង្រាយអ្នកសង្កេតការណ៍ចំនួន ប្រមាណ ៥៥០ នាក់ទូទាំងប្រទេស ជាពិសេសតាមបណ្តាឃុំនៅតំបន់ដាច់ស្រយាល ។

**គណៈកម្មាធិការខុមហ្វ្រែល** សូមសំដែងនូវការអបអរសាទរចំពោះលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៦ ដែលប្រព្រឹត្តទៅសំរេចបានបរិមាណច្រើន ដោយចំនួនអ្នកចុះឈ្មោះថ្មី (គិតរួមទាំងអ្នកមិនដែលចុះឈ្មោះសោះ និងអ្នកដែលបានផ្លាស់ប្តូរទីលំនៅ) មានអត្រាកើនឡើងរហូតដល់១.២១៤.២៥០នាក់ ស្មើនឹង ២១០% បើប្រៀបធៀប នឹងការប៉ាន់ប្រមាណរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) សំរាប់ឆ្នាំ ២០០៦ ដែលមានតែប្រមាណ ៥៧៧.៥០២ នាក់ប៉ុណ្ណោះ (យោងតារាងលទ្ធផលបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់គ.ជ.ប) ។

អត្រាចុះឈ្មោះច្រើនហួសការប៉ាន់ប្រមាណ លើកនេះឆ្លុះបញ្ចាំងឱ្យឃើញថា គ.ជ.ប មានកំហុសបច្ចេកទេស គណនា និងធ្វើស្ថិតិ ហើយបានធ្វើឱ្យប៉ះពាល់ដល់ការផ្គត់ផ្គង់ឯកសារជាទំរង់បែបបទនានាជួបប្រទះការខ្វះខាតច្រើន។

ខុមហ្វ្រែលសូមវាយតំលៃខ្ពស់ចំពោះ គ.ជ.ប ដែលបានសំរេចពន្យារពេលចុះឈ្មោះបោះឆ្នោតបួនថ្ងៃបន្ថែម បើទោះបីប្រតិទិនមានពេលវេលាចង្អៀតក៏ដោយ ។ ក្រៅពីភាពមិនប្រក្រតីដូចបានរៀបរាប់នៅក្នុងរបាយការណ៍ជា បឋមរបស់ ខុមហ្វ្រែល ចុះថ្ងៃទី ១៣ ខែ តុលា ២០០៦ (ដែលមានដូចជា ការមិនគោរពពេលវេលាធ្វើការរបស់ស្មៀន និងក្រុមប្រឹក្សាឃុំ-សង្កាត់ ការមិនគោរពគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃលេខ ០០៨ សណន ដោយជា រឿយៗមានការបិទទ្វារការិយាល័យចុះឈ្មោះបោះឆ្នោតនៅឃុំ-សង្កាត់មួយចំនួន ដោយមូលហេតុមានការកោះប្រជុំពី សំណាក់អាជ្ញាធរមូលដ្ឋាន និង/ឬពីគណបក្សនយោបាយ ឬ ដោយព្រឹត្តិហេតុផ្សេងៗ) ការសង្កេតរបស់ខុមហ្វ្រែល បានរកឃើញនូវភាពមិនប្រក្រតី និងបញ្ហាមួយចំនួនដែលបានកើតឡើងបន្តបន្ទាប់ទៀត ដែលបានបណ្តាលឱ្យបាត់បង់ នូវសិទ្ធិបោះឆ្នោត និងប៉ះពាល់ដល់ដំណើរការចុះឈ្មោះបោះឆ្នោត។ ភាពមិនប្រក្រតី កើតមានច្រើនជាងគេ គឺមាន រហូតដល់ ១៦ ករណី នៅខេត្តកំពង់ស្ពឺ បន្ទាប់មក គឺខេត្តរតនះគីរី ១៤ ករណី ខេត្តឧត្តរមានជ័យ ១៤ ករណី ខេត្តកំពង់ចាម ១៣ ករណី និង ១៨ខេត្ត/ក្រុង ទៀតកើតឡើងនូវភាពមិន ប្រក្រតីក្រោម ១០ ករណី។ ករណីទាំង នោះមានរៀបរាប់ដូចខាងក្រោមនេះ:

- **កង្វះឯកសារ:** យ៉ាងហោចណាស់ ខុមហ្វ្រែល បានសង្កេតឃើញថា ករណីខ្វះឯកសារក្នុងការបំពេញបែបបទដូចជាទំរង់ ១០១៨ ដើម្បីបានទទួលការចុះឈ្មោះបោះឆ្នោត មានចំនួន ២៦ ករណី បានកើតមានឡើងស្ទើរគ្រប់ខេត្ត/ក្រុង។
- **ការបដិសេធសិទ្ធិចុះឈ្មោះ:** ប្រជាពលរដ្ឋយ៉ាងតិច ៣.១៧០ គ្រួសារ នៅឃុំអំពិលប្រាំដើម ស្រុកបវេល ខេត្តបាត់ដំបង និងប្រជាពលរដ្ឋចំនួនប្រមាណ ៣.០០០ នាក់ ដែលត្រូវបានអាជ្ញាធរជម្លៀសពីសង្កាត់ទន្លេបាសាក់ ទៅសង្កាត់គោករកា ជាដើម។ល។ ត្រូវបានបដិសេធសិទ្ធិចុះឈ្មោះដោយសារបញ្ហាថា **គ្មានឯកសារបញ្ជាក់ទីលំនៅ** (ឬឯកសារបញ្ជាក់អត្តសញ្ញាណ)។
- **មានភាពមិនប្រក្រតីជាច់ដោយឡែកចំនួន ២ ករណី ដែលអាចប៉ះពាល់ដល់ដំណើរការបោះឆ្នោត បើសិនករណីនេះកើតឡើងច្រើននៅបណ្តាឃុំ/សង្កាត់ផ្សេងៗទៀត។** ករណីមួយនៅខេត្តកំពង់ចាម គឺមានការចុះឈ្មោះខុសទីកន្លែង (ឃុំ) ពីសំណាក់ស្មៀនឃុំវាលវង់ទៅឱ្យនិស្សិតសាលាពេទ្យចំនួន ៣០នាក់ ដែលពួកគេមានទីកន្លែងស្នាក់នៅបណ្តោះអាសន្ននៅឃុំកំពង់ចាម និងទាហានចំនួន ១០នាក់ ដែលមានទីតាំងនៅឃុំបឹងកុក។ ការចុះឈ្មោះរបៀបនេះត្រូវបានបកស្រាយដើម្បីធ្វើឱ្យត្រូវលទ្ធផលបោះឆ្នោត បើសិនគេគិតថាចំនួនអ្នកចុះឈ្មោះនេះ នឹងបោះឆ្នោតឱ្យគណបក្សប្រជាជនកម្ពុជា ក្នុងន័យធ្វើឱ្យមានការប្រែប្រួលដូចជា ឃុំវាលវង់ ដែល**ចំនួនសន្លឹកឆ្នោត**របស់គណបក្សប្រជាជនកម្ពុជា **តិចជាង**គណបក្សសមរង្ស៊ីជាងពាក់កណ្តាល បើយោងតាមលទ្ធផលបោះឆ្នោត២០០៣។ ករណីមួយទៀតគឺមានអំពើយកលុយកាក់ក្នុងការ ចុះឈ្មោះ ជាក់ស្តែងក្នុងឃុំយុទ្ធសាមគ្គី ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ស្មៀនឃុំបានទារយកប្រាក់ពីកម្មករកម្មការិនីចំនួន ១២៣ នាក់ ដែលក្នុងម្នាក់ៗចំនួន ១.០០០ រៀល នៅពេលដែល ពួកគេទៅចុះឈ្មោះបោះឆ្នោត។
- **ការរារាំងលើសកម្មភាពគណបក្សនយោបាយ:** គណបក្សនយោបាយធំៗ ពិសេសគណបក្សប្រជាជនកម្ពុជា និងគណបក្ស សម រង្ស៊ី បានធ្វើសកម្មភាពអប់រំ ផ្សព្វផ្សាយព័ត៌មាន និងជួយប្រជាពលរដ្ឋក្នុងការចុះឈ្មោះបោះឆ្នោត ដែលបានចូលរួមចំណែកបង្កើនអត្រាចុះឈ្មោះយ៉ាងច្រើន។ ប៉ុន្តែសកម្មភាពខ្លះរបស់គណបក្ស សម រង្ស៊ី ត្រូវបានបន្តការរារាំង និងហាមឃាត់ពីអាជ្ញាធរមូលដ្ឋានទៅវិញ។ យ៉ាងហោចណាស់មាន ៩ ករណី នៅតាមបណ្តាខេត្ត/ក្រុងមួយចំនួនដូចជា នៅក្រុងភ្នំពេញ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ជាដើម។ល។ អាជ្ញាធរមូលដ្ឋានបានរារាំងមិនឱ្យសកម្មជនគណបក្ស សម រង្ស៊ី ធ្វើសកម្មភាពផ្សព្វផ្សាយសេចក្តីអំពាវនាវឱ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត ដោយលើកឡើងថា គណបក្ស សម រង្ស៊ី ឆ្លៀតឱកាសធ្វើការឃោសនារកសំឡេងឆ្នោត។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ <u>គ្មានច្បាប់ ឬនីតិវិធីណាមួយចង្អុលបង្ហាញថា សកម្មភាពឃោសនារបស់គណបក្សនយោបាយក្នុងការងារបោះឆ្នោតខុសច្បាប់នោះទេ</u>។ ក្នុងកំឡុងពេលនេះផងដែរ ការ សង្កេតឃើញថា គណបក្សនយោបាយមានអសនៈក្នុងសភាបានធ្វើសកម្មភាពទាក់ទិនពង្រឹងបណ្តាញ និងឃោសនាអំពី ការងារគណបក្ស ពិសេសគណបក្សកាន់អំណាច (គណបក្សប្រជាជនកម្ពុជា) បាន និងកំពុងផ្សព្វផ្សាយសកម្មភាពនិងសមិទ្ធិផលនានា របស់គណបក្សខ្លួនតាមវិទ្យុ និងទូរទស្សន៍រដ្ឋ និងឯកជនជាច្រើន។
- **បរិយាកាសភ័យខ្លាច អសន្តិសុខនៅខេត្ត/ក្រុងមួយចំនួន:** នៅក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះនេះ **ខុមហ្វ្រែល** ក៏បានទទួលរបាយការណ៍អំពីករណីឃាតកម្ម គំរាមកំហែង បំភិតបំភ័យ និងអំពើហិង្សាទាក់ទិនសកម្មជនគណបក្សនយោបាយ ក្នុងបណ្តាខេត្ត/ក្រុងមួយចំនួនដូចជា នៅខេត្តកំពង់ចាម តាកែវ និងព្រៃវែង។ ករណីបំភិតបំភ័យប្រជាពលរដ្ឋជាច្រើននាក់ត្រូវបាន**បង្ខំឱ្យស្បថ** (ឱ្យផ្តិតមេដៃ និងតាមរយៈមធ្យោបាយផ្សេងទៀត) ពីសំណាក់អាជ្ញាធរមូលដ្ឋានដែលលំអៀងទៅគណបក្សនយោបាយ ឱ្យចូលជាសមាជិកគណបក្សនយោបាយរបស់ពួកគេជាពិសេសពីសំណាក់ប្រធានភូមិនៅក្នុងតំបន់មួយចំនួននៃខេត្តតាកែវ។ រីឯ**ករណីទំលាក់ផ្លាក**គណបក្សហ៊្វុនស៊ិនប៉ិចមានចំនួនមួយ ករណី

នៅឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម និងសកម្មជនគណបក្សសម រង្ស៊ីត្រូវបាន**ចាប់ខ្លួនចំនួន ១ ករណី** គឺក្នុងឃុំរការពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម លើឈ្មោះ ញិន សារឿន ភេទប្រុស អាយុ ៣៥ឆ្នាំ។

**ករណីអំពើហិង្សាទៅលើសកម្មជនគណបក្សនយោបាយមានចំនួន ៣ ករណី** ដែលបានកើតឡើង នៅខេត្តព្រៃវែង ចំនួន ២ ករណី គឺទៅលើឈ្មោះ សំបូរ សុមៈ ភេទ ប្រុស នៅភូមិលេខ៦ ឃុំកំពង់លាវ ស្រុកកំពង់លាវ និងឈ្មោះ គង់ ប្រ៊ិច ភេទស្រី នៅភូមិពពិល ឃុំព្រៃកណ្ដោល ស្រុកកំពង់លាវ និង ខេត្តកំពង់ចាម ១ ករណី ទៅលើ ឈ្មោះ លាង ហួ ភេទប្រុស នៅ ភូមិថ្មីកណ្ដាល ឃុំព្រះធាតុ ស្រុកអូររាំងឪ។

**មានករណីឃាតកម្មចំនួន ២** ដែលជនរងគ្រោះគឺជាសកម្មជនឃុំ គណបក្ស**សម រង្ស៊ី** ឈ្មោះ ធុង ធា ភេទប្រុស អាយុ២៧ ឆ្នាំ នៅក្នុងឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម ១ ករណី និងឈ្មោះ វិន បុរី ភេទប្រុស អាយុ ២១ឆ្នាំ នៅក្នុងភូមិទុនស្រូវ ឃុំគោកគង់ខាងកើត ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ១ ករណី។

- **ដំណើរការដោះស្រាយបណ្ដឹងៈ** ក្នុងកំឡុងពេលចុះឈ្មោះបោះឆ្នោត និង បិទបញ្ជីឈ្មោះបោះឆ្នោតដំបូងនេះ ខុមហ្វ្រែល បានទទួល និងតាមសង្កេត បណ្ដឹងយ៉ាងតិចចំនួន ៧៦ ករណី ដែលបណ្ដឹងទាំងនោះប្ដឹងដោយគណបក្សសមរង្ស៊ី។ ខេត្ត/ក្រុងដែលមានបណ្ដឹងទាំងនោះរួមមាន ក្រុងភ្នំពេញ ក្រុងព្រះសីហនុ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ចាម ព្រៃវែង សៀមរាប ពោធិ៍សាត់ កណ្ដាល តាកែវ កំពង់ឆ្នាំង និងខេត្តស្វាយរៀង។ ការសង្កេតឃើញថា ប្រជាពលរដ្ឋសាមញ្ញមិនបានលើកទឹកចិត្តឱ្យធ្វើការប្ដឹងដោយខ្លួនឯងបានទេ នេះគឺដោយសារតែនីតិវិធីបណ្ដឹងមានភាពស្មុគ្រស្មាញ និងចំណាយពេលវេលា និងប្រាក់កាសច្រើនក្នុងករណីប្ដឹងបន្តមក គ.ជ.ប ព្រមទាំងពុំមានការយកចិត្តទុកដាក់នូវបណ្ដឹងផ្ទាល់មាត់របស់ប្រជាពលរដ្ឋពីសំណាក់អាជ្ញាធរក្រុមប្រឹក្សាឃុំ/សង្កាត់។

កម្មវត្ថុនៃបណ្ដឹងក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោតទាំងនោះ ភាគច្រើនផ្ដោតទៅលើការសុំពន្យារពេលចុះឈ្មោះបោះឆ្នោត ការខ្វះឯកសារ (ទំរង់ ១០១៨ និង ១០១៩) និងការតវ៉ាសុំសិទ្ធិចុះឈ្មោះអោយ ដោយមូលហេតុគ្មាន/ឬខ្វះឯកសារបញ្ជាក់ (ជាពិសេសករណីប្រជាពលរដ្ឋដែលត្រូវបានអាជ្ញាធរជម្លៀសចេញពីភូមិសំបុកចាប សង្កាត់ទន្លេបាសាក់ ទៅភូមិអណ្ដូង សង្កាត់គោករកា)។ បណ្ដឹងជំទាស់ក្នុងកំឡុងពេលបិទបញ្ជីដំបូង ភាគច្រើនទាក់ទិននឹងការសុំលុបឈ្មោះជនសង្ស័យជាជនជាតិវៀតណាមដែលពុំមានលក្ខណៈសម្បត្តិ ឬឯកសារបញ្ជាក់សញ្ជាតិខ្មែរច្បាស់លាស់។

ក្នុងចំណោមបណ្ដឹងទាំងនោះ ក្រុមប្រឹក្សាឃុំ/សង្កាត់ និងគ.ជ.ប បានប្រជុំសម្រេច និងបើកសវនាការ យ៉ាងតិចចំនួន ៣៧ បណ្ដឹង ដោយយល់ព្រមចុះឈ្មោះអោយប្រជាពលរដ្ឋចំនួន ១១ រូប (ករណីនៅក្រុង ព្រះសីហនុ) និងសំរេចលុបឈ្មោះអ្នកបោះឆ្នោត ដែលគ្មានលក្ខណៈសម្បត្តិ និងឯកសារបញ្ជាក់គ្រប់គ្រាន់ចំនួន ១.២៣២ នាក់ គិតត្រឹមថ្ងៃទី ១៥ ខែវិច្ឆិកា ដោយសារមូលហេតុអ្នកទាំងនោះបានស្លាប់ ផ្លាស់ប្ដូរទីលំនៅ គ្មានឯកសារបញ្ជាក់ជាដើម។ លទ្ធផលនៃការប្ដឹងជំទាស់ គឺបានមកពីការប្រមូលភស្តុតាងប្រឆាំងថាជននោះ គ្មានឯកសារបញ្ជាក់អំពីសញ្ជាតិខ្មែរផងដែរ។

ខុមហ្វ្រែល យល់ឃើញថា ទោះបីមានចំណាត់ការដោះស្រាយតាមនីតិវិធី តែការសំរេចខ្លះបានត្រឹមសំរុះសំរួលរក្សាទុកឈ្មោះ ប៉ុន្តែគ្មានការដាក់ពិន័យទៅលើការប្រព្រឹត្តិរបស់អាជ្ញាធរមូលដ្ឋាន ឃុំ/សង្កាត់ ដែលមានចេតនាខុសច្បាប់ លុបឈ្មោះ ឬ/និងមិនព្រមចុះ ឈ្មោះឱ្យអ្នកបោះឆ្នោត។